ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

- សំណុំរឿងព្រហ្មទណ្ឌលេខ ៩៧០

ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២

- សំណុំរឿងជំនុំជម្រះលេខ ៧៦៩

ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២

- សាលក្រមព្រហ្មទណ្ឌលេខ ០៥"ង"/១៨

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាបនាសាលសវនាការលេខ:ខ០២។

កាលបរិច្ឆេទបើកសវនាការនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៩ និង ៣០នាទីព្រឹក។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ២ និង ៣០នាទីរសៀល។

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ។

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ: ៩៧០ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដែលមានជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ[redacted]

[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី១២ មុខរបរ មុខរបរ មិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ [redacted] **ឈឹម** (រ) ម្តាយឈ្មោះ [redacted] **ស៊ីល្ហួត** (រ) ទោសពីមុន គ្មាន។ (ក្នុងឃុំ)

ជាប់ចោទពីបទ៖ **ប៉ុនប៉ងលួចដោយមានស្ថានទម្ងន់ទោស (ប្រើប្រាស់កូនសោរក្លែង)** ប្រព្រឹត្តនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៧ មាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឆារ៉ៃ** ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។ (មិនប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ)។

-សាក្សីឈ្មោះ [redacted] **ឆាយ៉ា** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

-សាក្សីឈ្មោះ [redacted] **សាន** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

-តាមដីកាសន្និដ្ឋានស្ថាពរលេខ : ៧១៧ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-តាមដីកាដំណោះស្រាយលេខ : ៤៤៧៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ : ៨៥៦ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## ឯអង្គហេតុកើតមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ១០នាទី ឈ្មោះ **សូត សោភ័ណ្ឌ** បានធ្វើសកម្មភាពយកកូនសោទៅចាក់សោរតូបលក់ដូររបស់ជនរងគ្រោះឈ្មោះ [redacted] **ឆារ៉ៃ** ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។ ពេលដែលជនត្រូវចោទកំពុងធ្វើសកម្មភាពចាក់សោរតូបរបស់ជនរងគ្រោះ ហើយក៏ត្រូវបានឈ្មោះ [redacted] **ឆាយ៉ា** ជាកូនរបស់ជនរងគ្រោះឃើញបានទៅដាស់ឪពុក និងហៅអ្នកជិតខាងជួយចាប់ជនត្រូវចោទប្រគល់ជនសមត្ថកិច្ច និងបានដកហូតកូនសោរចំនួន ៦ ម៉ូតូម៉ាកហុងដាស្គុបពីចំនួន ១ គ្រឿង ពណ៌ស ពាក់ស្លាកលេខ សៀមរាប 1AI-3163 និងកាបូបស្ពាយពណ៌ខ្មៅចំនួន ១ ។ ក្រោយពេលឃាត់ខ្លួនជនត្រូវចោទបានសារភាពថា ខ្លួនពិតបានយកកូនសោរទៅចាក់សោរតូបរបស់ជនរងគ្រោះប្រាកដមែន ។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ បានឆ្លើយថា៖ ខ្លួនត្រូវចាប់ខ្លួននៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាព្រលប់។ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូចូលតាមផ្លូវបុរីសៀងណាំ ហើយមេឃភ្លៀងខ្លួនក៏ចូលជ្រកនៅផ្ទះមួយជិតកន្លែងគេលក់ដូរ ដោយផ្ទះនេះមានចាក់សោរ ។ ឆ្លៀតពេលនោះខ្លួនបានយកកូនសោរទៅចាក់សោរទ្វារបំណងយកអីវ៉ាន់ក៏ត្រូវគេស្រែក ហើយមានមនុស្សជាច្រើនមកចាប់ខ្លួនតែម្តង ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ឆាវ៉ែ បានឆ្លើយថា៖ នៅវេលាម៉ោង ៩ និង ១០ នាទីយប់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ខ្លួនកំពុងដេកនៅក្នុងផ្ទះល្វែងដែលជួលគេលក់អីវ៉ាន់នៅភូមិខ្មារ ពេលនោះកូនរបស់ខ្លួនឈ្មោះ [redacted] ឆាយ៉ា បានដាស់ហៅខ្លួនប្រាប់ថា មានមនុស្សចាក់សោរទ្វារនៅតូបលក់របស់ខ្លួនដែលចាក់សោរនៅទល់មុខផ្ទះល្វែងខ្លួនដេក។ ខ្លួនបានឃើញក៏ស្ទុះទៅស្រវ៉ាចាប់កូនសោរមួយចង្កោមដែលជនល្មើសកំពុងចាក់ហើយកូនរបស់ខ្លួនបានស្ទុះទៅដកសោរម៉ូតូរបស់វា និងបានស្រែកឱ្យអ្នកជិតខាងជួយក៏ចាប់បានជនល្មើសហើយប្រគល់ឱ្យសមត្ថកិច្ចប៉េអ៊ឹម។ទ្រព្យសម្បត្តិរបស់ខ្លួនមិនមានបាត់បង់ទេគ្រាន់តែខូចសោរមួយប្រើមិនកើតដែលខ្លួនទិញតម្លៃ ២ ដុល្លារអាមេរិក។ ខ្លួនមិនទាមទារសំណងជម្ងឺចិត្តអ្វីទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ឆាយ៉ា បានឆ្លើយថា៖ នៅវេលាម៉ោង ៩ និង ១០ នាទីយប់ថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២២ ខ្លួនកំពុងអង្គុយលេងនៅមុខផ្ទះល្វែងជួលបានឃើញមនុស្សប្រុសម្នាក់ជិះម៉ូតូម៉ាកស្កុបពីមកឈប់មុខហាងលក់ចាប់ហួយរបស់ឪពុកម្តាយខ្លួនដែលចាក់សោរឈប់លក់នៅទល់មុខផ្ទះល្វែង ហើយបានចុះទៅចាក់សោរទ្វារតូបលក់ខ្លួនក៏បានដាស់ហៅឪពុកខ្លួន។ ឪពុកខ្លួនបានស្ទុះទៅចាប់ចោរ ឯខ្លួនទៅដកកូនសោរម៉ូតូរបស់ចោរ និងបានស្រែកហៅឱ្យអ្នកជិតខាងជួយ និងចាប់បានចោរក៏ទូរស័ព្ទហៅខាងសមត្ថកិច្ចប៉េអ៊ឹម។ ចោរនេះទើបតែចាក់សោរធ្វើឱ្យខូចមិនទាន់បានយកទ្រព្យសម្បត្តិអ្វីទេ ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សាន បានឆ្លើយថា៖ នៅវេលាម៉ោង ៩ និង ១០ នាទីយប់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ខ្លួនបានត្រឡប់មកពីមើលការប្រគុំតន្ត្រីនៅក្បែរវិមានមង្គលមកដល់ជិតផ្ទះឈ្មោះ [redacted] ឆាវ៉ែ បានឮឈ្មោះ [redacted] ឆាយ៉ា ស្រែកឱ្យជួយចាប់ចោរគាស់ទ្វារខ្លួនក៏រត់មកជួយ ហើយចាប់បានចោរដែលមិនស្គាល់ឈ្មោះ និងដកហូតបានម៉ូតូរបស់ចោម៉ាកស្កុបពីដែលជិះមកធ្វើសកម្មភាពរួមទាំងកូនសោរមួយចង្កោម ហើយបានទូរស័ព្ទហៅសមត្ថកិច្ចប៉េអ៊ឹមមកទទួលយកចោរដើម្បីចាត់ការតាមច្បាប់ ។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពីបានធ្វើការពិភាក្សាដេញដោលក្នុង ពេលសវនាការរួចមក ផ្អែកលើភស្តុតាង ចម្លើយសារភាពរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់ឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តមែន ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទ តាមដីកាសន្និដ្ឋានស្ថាពរទុកដដែល។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា:** តាមរយៈការពិភាក្សាដេញដោល និងការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងឃើញថា ការចោទប្រកាន់មកលើឈ្មោះ [redacted] **សោភ័ណ្ឌ** ពីបទ ប៉ុនប៉ងលួចដោយមានស្ថានទម្ងន់ទោស (ប្រើប្រាស់កូនសោរក្លែង) តាមមាត្រា២៧ មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ គឺមិនត្រឹមត្រូវនោះទេ ដោយហេតុថា ផ្អែកតាមភស្តុតាងដែលមាននៅក្នុងសំណុំរឿង គឺឈ្មោះ [redacted] **សោភ័ណ្ឌ** ពុំបានប្រព្រឹត្តអំពើ ប៉ុនប៉ងលួចដោយមានស្ថានទម្ងន់ទោស (ប្រើប្រាស់កូនសោក្លែង) ដូចការចោទប្រកាន់របស់អយ្យការនោះទេ ម្យ៉ាងទៀតអំពើរបស់ឈ្មោះ [redacted] **សោភ័ណ្ឌ** ពុំទាន់បានបង្ករព្យសនកម្មជាក់លាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយទេ ហេតុនេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិស្នើសុំ លោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖ ១/កែប្រែបទចោទពីបទ ប៉ុនប៉ងលួចដោយមានស្ថានទម្ងន់ទោស (ប្រើប្រាស់កូនសោរ



Scanned with CamScanner

ក្លែង) មកបទ ប៉ុនប៉ងលួច តាមបញ្ញត្តិមាត្រា២៧ និងមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ព្រមទាំងបន្ធូរបន្ថយទោស និង ២/ប្រកាសព្យួរទោសដល់ឈ្មោះ [redacted] **សោភ័ណ្ឌ** ដោយក្ដីអនុគ្រោះ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្ដាប់ចម្លើយរបស់សាក្សី។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

១-កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ១០នាទី ពិតជាមានករណី ឈ្មោះ [redacted] **សោភ័ណ្ឌ** បានធ្វើសកម្មភាពយកកូនសោទៅចាក់សោរតូបលក់ដូររបស់ជនរងគ្រោះឈ្មោះ [redacted] **ឆារ៉េ** ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ប្រាកដមែន។

២-នៅពេលសវនាការជនជាប់ចោទបានបដិសេធថា ខ្លួនមិនបានធ្វើសកម្មភាពដោយយកកូនសោរផ្សេងទៅចាក់ទៅលើកូនសោរតូបរបស់ជនរងគ្រោះនោះទេ។ ដែលហេតុថានៅក្នុងថ្ងៃនោះគឺខ្លួនបានជ្រកភ្លៀងនៅសំយាបតូបរបស់ជនរងគ្រោះប៉ុណ្ណោះ ដូច្នេះការចោទមកលើខ្លួន គឺមិនត្រឹមត្រូវទេ។ ក៏ប៉ុន្តែនាពេលចុងក្រោយជនជាប់ចោទបែរជាឆ្លើយទទួលស្គាល់ថា ខ្លួនពិតជាបានយកកូនសោរមួយចង្កោមដែលជារបស់ខ្លួន ដែលមិនមែនជាកូនសោរដើមយកទៅចាក់នឹងមេសោរដែលចាក់ជាប់នឹងទ្វារតូប ក៏ត្រូវបានម្ចាស់តូបគេឃើញទាន់។ ការឆ្លើយសារភាពទទួលស្គាល់របស់ជនជាប់ចោទទៅលើអង្គហេតុខាងលើនេះ គឺមានភាពស៊ីសង្វាក់ទៅនឹងសាក្សី ដែលបានឃើញហេតុការណ៍នេះ ហើយក៏មានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងដែលមន្ត្រីនគរបាលយុត្តិធម៌បានកសាងបញ្ជូនមកមានដូចជា កូនសោរ ដែលជារបស់ជនជាប់ចោទ និងមេសោរដែលចាក់ជាប់នឹងតូប ដែលជនជាប់ចោទព្យាយាមក្នុងការចាក់ចូល។

៣-ក្រោយការឃាត់ខ្លួនសមត្ថកិច្ចបានដកហូតនូវវត្ថុតាងដូចជា ម៉ូតូម៉ាកហុងដាស្កុបពីអាយ ស៊េរីឆ្នាំ២០២០ មានសោរ ពណ៌ស មានកញ្ចក់ កាំវន្ទះពណ៌ខ្មៅ ផ្លាកលេខ 1AI-3163 លេខតួ 8184371, សោរមួយចង្កោម(ចំនួន៥), កូនសោរម៉ូតូចំនួន១, និងរបស់ប្រើប្រាស់មួយចំនួន របស់ទាំងអស់នេះ គឺជនជាប់ចោទប្រើប្រាស់ជាមធ្យោបាយនៅក្នុងការប្រព្រឹត្តបទល្មើស ហើយក៏ស៊ីសង្វាក់គ្នាទៅនឹងចម្លើយសារភាពរបស់ជនជាប់ចោទដែលបានឆ្លើយទទួលស្គាល់ទៅនឹងអង្គហេតុខាងលើ វត្ថុតាងនេះគប្បីធ្វើការរឹបអូសដោយមិនប្រគល់ឱ្យជនជាប់ចោទវិញឡើយ។ ចំណែកឯវត្ថុតាងដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ [redacted] សោភ័ណ្ឌ, ប័ណ្ណសមាជិក ប.ស.ស ឈ្មោះ [redacted] សោភ័ណ្ឌ, កាត ABA BANK ចំនួន១ វត្ថុទាំងអស់នេះ

មិនមែនជាមធ្យោបាយក្នុងការប្រព្រឹត្តិបទល្មើសរបស់ជនជាប់ចោទឡើយ ហើយក៏មិនមែនជាវត្ថុដែលបង្ករដល់គ្រោះថ្នាក់នៃសង្គមផងដែរ គប្បីត្រូវប្រគល់ឲ្យជនជាប់ចោទប្រើប្រាស់វិញ។

៤-កាលដែរជនរងគ្រោះបានឆ្លើយបំភ្លឺគ្រប់ដំណាក់កាល ព្រមទាំងមិនធ្វើការទាមទារសំណងពីជនជាប់ចោទនោះ គឺដោយសារតែព្យសនកម្មដែលបានកើតឡើងមានលក្ខណៈតូចតាចមិនបង្ករនូវការខូចខាតធ្ងន់ធ្ងរដល់ជនរងគ្រោះនោះទេ។

៥-តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ឆារ៉ៃ បានឆ្លើយថា៖ នៅវេលាម៉ោង ៩ និង ១០ នាទីយប់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ខ្លួនកំពុងដេកនៅក្នុងផ្ទះល្វែងដែលជួលគេលក់អីវ៉ាន់នៅភូមិខ្មារ ពេលនោះកូនរបស់ខ្លួនឈ្មោះ [redacted] ឆាយ៉ា បានដាសហៅខ្លួនប្រាប់ថា មានមនុស្សចាក់សោរទ្វារនៅតូបលក់របស់ខ្លួនដែលចាក់សោរនៅទល់មុខផ្ទះល្វែងខ្លួនដេក។ ខ្លួនបានឃើញក៏ស្ទុះទៅស្រវ៉ាចាប់កូនសោរមួយចង្កោមដែលជនល្មើសកំពុងចាក់ ហើយកូនរបស់ខ្លួនបានស្ទុះទៅដកសោរម៉ូតូរបស់វា និងបានស្រែកឱ្យអ្នកជិតខាងជួយក៏ចាប់បានជនល្មើសហើយប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍។ទ្រព្យសម្បត្តិរបស់ខ្លួនមិនមានបាត់បង់ទេគ្រាន់តែខូចសោរមួយប្រើមិនកើតដែលខ្លួនទិញតម្លៃ ២ ដុល្លារអាមេរិក។ ខ្លួនមិនទាមទារសំណងជម្ងឺចិត្តអ្វីទេ។

៦-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ឆាយ៉ា បានឆ្លើយថា៖ នៅវេលាម៉ោង ៩ និង ១០ នាទីយប់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ខ្លួនកំពុងអង្គុយលេងនៅមុខផ្ទះល្វែងជួលបានឃើញមនុស្សប្រុសម្នាក់ជិះម៉ូតូម៉ាកស្កុបពីមកឈប់មុខហាងលក់ចាប់ហួយរបស់ឪពុកម្តាយខ្លួនដែលចាក់សោរឈប់លក់នៅទល់មុខផ្ទះល្វែង ហើយបានចុះទៅចាក់សោរទ្វារតូបលក់ខ្លួនក៏បានដាស់ហៅឪពុកខ្លួន។ ឪពុកខ្លួនបានស្ទុះទៅចាប់ចោរ ឯខ្លួនទៅដកកូនសោរម៉ូតូរបស់ចោរ និងបានស្រែកហៅឱ្យអ្នកជិតខាងជួយ និងចាប់បានចោរក៏ទូរស័ព្ទហៅខាងសមត្ថកិច្ចប៉ុស្តិ៍។ ចោរនេះទើបតែចាក់សោរធ្វើឱ្យខូចមិនទាន់បានយកទ្រព្យសម្បត្តិអ្វីទេ ។

៧-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សាន បានឆ្លើយថា៖ នៅវេលាម៉ោង ៩ និង ១០ នាទីយប់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ខ្លួនបានត្រឡប់មកពីមើលការប្រគុំតន្ត្រីនៅក្បែរវិមានមង្គលមកដល់ជិតផ្ទះឈ្មោះ [redacted] ឆារ៉ៃ បានឮឈ្មោះ [redacted] ឆាយ៉ា ស្រែកឱ្យជួយចាប់ចោរគាស់ទ្វារខ្លួនក៏រត់មកជួយ ហើយចាប់បានចោរដែលមិនស្គាល់ឈ្មោះ និងដកហូតបានម៉ូតូរបស់ចោម៉ាកស្កុបពីដែលជិះមកធ្វើសកម្មភាពរួមទាំងកូនសោរមួយចង្កោម ហើយបានទូរស័ព្ទហៅសមត្ថកិច្ចប៉ុស្តិ៍មកទទួលយកចោរដើម្បីចាត់ការតាមច្បាប់ ។

តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី គឺមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងចម្លើយសារភាពជនជាប់ចោទ ព្រមទាំងវត្ថុតាងដែលសមត្ថកិច្ចបានដកហូតពីជនជាប់ចោទក្រោយពេលធ្វើការឃាត់ខ្លួនរួច។

**៨-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពីបានធ្វើការពិភាក្សាដេញដោលក្នុង ពេលសវនាការរួចមក ផ្អែកលើភស្តុតាង ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី បញ្ជាក់ឱ្យឃើញថាជនជាប់ចោទពិតជាបាន ប្រព្រឹត្តមែន ដូចនេះ តំណាងអយ្យការសុំរក្សាបទចោទ តាមដីកាសន្និដ្ឋានស្ថាពរទុកដដែល។ គប្បីតុលាការពិចារណា។

៩-ចំពោះការស្នើសុំ ០២ចំណុច របស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទមានដូចជា៖ ចំណុចទី១ តុលាការយល់ឃើញថា មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] សោភ័ណ្ឌ បានស្នើសុំឱ្យតុលាការប្តូរបទចោទប្រកាន់

ត្រង់ចំណុចនេះតុលាការមិនអាចពិចារណាលើចំណុចនេះទេ ព្រោះព្យសនកម្មដែលជនត្រូវចោទឈ្មោះ [redacted] សោភ័ណ្ឌ បានធ្វើសកម្មភាពគឺចាក់សោរគូបរបស់ជនរងគ្រោះខូចខ្ទេចខ្ទីអស់ ដូចនេះជាសកម្មភាពគាស់ទម្លុះទម្លាយ ធ្វើឲ្យខាតប្រយោជន៍ដល់ជនរងគ្រោះ ដូចនេះគប្បីតុលាការរក្សាបទចោទប្រកាន់ដដែល តាមដីកា ដំណោះស្រាយ។ ដូចនេះគប្បីតុលាការមិនពិចារណា។ ចំពោះចំណុចទី២ អំពីការព្យួរទោស យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ ទើបតែប្រព្រឹត្តបទល្មើសលើកទី១ ហើយជននេះមិនទាន់មានការផ្តន្ទាទោស ជាស្ថាពរឲ្យជាប់ពន្ធនាគារក្នុងរយៈពេល ០៥ឆ្នាំ មុនអំពើល្មើស ដូចនេះគប្បីតុលាការ ពិចារណាអំពីស្ថានសម្រាលនៃការព្យួរទោសនេះ។

១០-មានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ ពីបទ : **ប៉ុនប៉ងលួចដោយមានស្ថានទម្ងន់ទោស (ប្រើប្រាស់កូនសោរក្លែង)** ប្រព្រឹត្តនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៧ មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ ជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ មិនធ្លាប់មានទោសពីមុន និងមិនទាន់មានការផ្តន្ទាទោសជាស្ថាពរឲ្យជាប់ពន្ធនាគារ ក្នុងរយៈពេល ០៥ឆ្នាំ មុនអំពើល្មើស។ ប៉ុន្តែជនជាប់ចោទបានឆ្លើយសារភាពទទួលស្គាល់កំហុសរបស់ខ្លួន ម្យ៉ាងទៀតព្យសនកម្មដែលបានកើតឡើងគឺមានលក្ខណៈតូចតាចត្រឹមតែការខូចខាតមេសោរមួយប៉ុណ្ណោះ ហើយក្នុងសវនាការជនជាប់ចោទបានស្នើសុំតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ដូច្នេះតុលាការពិចារណាពីការសម្រាលទោស។

## សាលាដំបូងខេត្តសៀមរាប

## វិនិច្ឆ័យសេចក្តី

១/-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ ភេទប្រុស ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ តែទោសនេះ៖

**-អនុវត្តទោសពន្ធនាគាររយៈពេល ០២(ពីរ)ឆ្នាំ។**

**-ទោសដែលនៅសល់ អនុវត្តទោសព្យួរធម្មតា។**

ពីបទ៖ **ប៉ុនប៉ងលួចដោយមានស្ថានទម្ងន់ទោស (ប្រើប្រាស់កូនសោរក្លែង)** ប្រព្រឹត្តនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៧ មាត្រា៣៥៣ មាត្រា៣៥៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

២/-វត្ថុចាប់យករួមមាន៖

-ម៉ូតូម៉ាកហុងដាស្កុបពីអាយ ស៊េរីឆ្នាំ២០២០ មានសោរ ពណ៌ស មានកញ្ចក់ កាំរន្ទះពណ៌ខ្មៅ ផ្លាកលេខ 1AI-3163 លេខតួ 8184371, សោរមួយចង្កោម(ចំនួន៥), កូនសោរម៉ូតូចំនួន១, និងរបស់ប្រើប្រាស់មួយចំនួន តុលាការសម្រេចរឹបអូស។

-ចំណែកឯអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ [redacted] សោភ័ណ្ឌ, ប័ណ្ណសមាជិក ប.ស.ស ឈ្មោះ [redacted] សោភ័ណ្ឌ, កាត ABA BANk ចំនួន១ តុលាការសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។

៣/-សាលក្រមនេះជំនុំជម្រះជាសាធារណៈ ដោយចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆារ៉ែ។

ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប,ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]